# សេចក្ដីសង្ឃឹម

អែលឌើរ ស្ទីវិន អ៊ី ស្នូ
នៃពួកចិតសិបនាក់

*ក្ដីសង្ឃឹមយើងលើដង្វាយធួនផ្ដល់អំណាចឲ្យយើង ជាមួយនឹងជោគជ័យដ៏អស់កល្ប ។*

គ្រួសារយើងធំឡើងក្នុងតំបន់ខ្សាច់ដ៏មានកម្ពស់ខ្ពស់នៃភាគខាងត្បូងរដ្ឋ យូថាហ៍ ។ វាកម្រនឹងមានភ្លៀងណាស់ ហើយសង្ឃឹមថានឹងមានភ្លៀងគ្រប់គ្រាន់ក្នុងរដូវក្ដៅក្រោយ ។ឥឡូវ យើងសង្ឃឹមឲ្យមានភ្លៀង យើងអធិស្ឋានឲ្យមានភ្លៀង និងពេលអស់សង្ឃឹម យើងបានតមអាហារឲ្យមានភ្លៀង ។

មានរឿងមួយបានដំណាលថា មានជីតាម្នាក់បាននាំចៅប្រុសគាត់អាយុប្រាំឆ្នាំដើរលេងជុំវិញក្រុង ។ ទីបំផុត ពួកគេបានមកដល់ហាងលក់អីវ៉ាន់តូចមួយនៅផ្លូវធំ ដែលពួកគេបានឈប់ទិញទឹកត្រជាក់ ។ មានឡានមួយមកពីក្រៅក្រុងបានបើកចូលមក ហើយអ្នកបើកបរបាននិយាយទៅជីតានោះ ។ ដោយលើកដៃចង្អុលទៅដុំពពកតូចមួយនៅលើមេឃ នោះជនចម្លែកនោះបានសួរថា « តើអ៊ំគិតថានឹងមានភ្លៀងទេ ? » បុរសចំណាស់នោះតបថា « អ៊ំពិតជាសង្ឃឹមថាវានឹងកើតឡើង សម្រាប់អ៊ំគឺមិនអីទេ អ៊ំធ្លាប់ឃើញហើយ ។ តែចៅអ៊ំមិនធ្លាប់ឃើញនៅឡើយទេ » ។

ក្ដីសង្ឃឹមគឺជាអារម្មណ៍មួយដែលនាំភ័ព្វសំណាងមកក្នុងជីវិតប្រចាំថ្ងៃយើង ។ វាត្រូវបានឲ្យនិយមន័យថា « ជាអារម្មណ៍ថាព្រឹត្តិការណ៍នានានឹងប្រសើរឡើង » ។ពេលយើងអនុវត្តក្ដីសង្ឃឹម យើង « មើលទៅមុខដោយមានក្ដីប្រាថ្នា និងការជឿជាក់ត្រឹមត្រូវ » ( dictionary.com ) ។ ដូច្នេះ ក្ដីសង្ឃឹមនាំយកឥទ្ធិពលនៃការស្រាកស្រាន្តដ៏ជាក់លាក់មួយមកក្នុងជីវិតយើង ពេលយើងមើលឆ្ពោះទៅអនាគតដោយជឿជាក់ ។

ពេលខ្លះ យើងសង្ឃឹមលើអ្វីដែលយើងមានការគ្រប់គ្រងតិចតួចបំផុត។ យើងសង្ឃឹមឲ្យមានអាកាសធាតុល្អ ។ យើងសង្ឃឹមឲ្យមានរដូវក្ដៅឆាប់ ។យើងសង្ឃឹមថាក្រុមកីឡាដែលយើងចូលចិត្តនឹងឈ្នះពានបាល់ទាត់ពិភពលោក ឈ្នះពានជើងឯកបាល់ឱប ឬកីឡាវាយកូនបាល់ ។

ក្ដីសង្ឃឹមបែបនេះធ្វើឲ្យជីវិតរបស់យើងមានន័យ ហើយជារឿយៗអាចនាំទៅរកឥរិយាបថខុសធម្មតា ឬមិនសមហេតុផល ។ឧទាហរណ៍ ឪពុកក្មេកខ្ញុំគឺចូលចិត្តកីឡាណាស់ តែគាត់ជឿថាបើគាត់*មិន*មើលក្រុមកីឡាវាយកូនបាល់ដែលគាត់ចូលចិត្តតាមទូរទស្សន៍ ភាគច្រើនក្រុមនោះនឹងឈ្នះ ។
ពេលខ្ញុំមានអាយុដប់ពីរឆ្នាំ ខ្ញុំចចេសពាក់ស្រោមជើងដដែលដោយមិនបានសំអាត ទៅការប្រកួតកីឡាវាយកូនបាល់គ្រប់ពេលដោយសង្ឃឹមថានឹងបានឈ្នះ ។

ពេលខ្លះទៀត ក្ដីសង្ឃឹមយើងអាចនាំទៅរកក្ដីស្រមៃដែលអាចបំផុសគំនិតដល់យើង និងដឹកនាំឲ្យធ្វើសកម្មភាព ។ បើយើងសង្ឃឹមថានឹងធ្វើបានល្អនៅសាលា ក្ដីសង្ឃឹមនោះអាចសម្រេចបានដោយការខិតខំសិក្សានិងការលះបង់ ។បើយើងមានក្ដីសង្ឃឹមចង់លេងឲ្យក្រុមជើងឯក ក្ដីសង្ឃឹមនោះអាចនាំទៅរកការហ្វឹកហាត់ ការលះបង់ ការរួមដៃគ្នាជាបន្តបន្ទាប់រហូតដល់បានជោគជ័យ ។

រ៉ចជឺ បាននីស្ដឺ ជានិស្សិតពេទ្យម្នាក់ក្នុងប្រទេសអង់គ្លេសដែលមានក្ដីសង្ឃឹមមួយយ៉ាងធំ ។ គាត់ប្រាថ្នាចង់ក្លាយជាមនុស្សដំបូងគេដែលអាចរត់ក្នុងចម្ងាយ 1.61 គ.ម. ដោយប្រើពេលតិចជាងបួននាទី ។ភាគច្រើននៅពាក់កណ្ដាលដើមទសវត្សរ៍ទីម្ភៃ អ្នកដែលចូលចិត្តកីឡាបានទន្ទឹងរង់ចាំនូវថ្ងៃដែលមានមនុស្សម្នាក់អាចអាចរត់ក្នុងចម្ងាយ 1.61 គ.ម. ដោយប្រើពេលតិចជាងបួននាទី ។អស់រយៈពេលជាច្រើនឆ្នាំមានអ្នករត់ប្រណាំងឆ្នើមជាច្រើនបានខិតជិតដល់ចំណុចនោះ តែនៅតែប្រើពេលបួននាទីដដែល ។ បាននីស្ដឺ បានខិតខំរៀបចំការហ្វឹកហាត់មួយដ៏លំបាក ដោយសង្ឃឹមថានឹងសម្រេចបានគោលដៅរបស់គាត់ក្នុងការបង្កើតឯកត្តកម្មពិភពលោកថ្មីមួយ ។មានមនុស្សមួយចំនួនក្នុងសហគមន៍កីឡាបានចាប់ផ្ដើមគិតថានឹងគ្មាននរណាម្នាក់អាចបំបែកឯកត្តកម្មនេះបានឡើយ ។ ពួកអ្នកជំនាញថែមទាំងបានសន្និដ្ឋានថា រាងកាយមនុស្សមិនអាចរត់ក្នុងល្បឿនបែបនេះនៅលើចម្ងាយផ្លូវនេះឡើយ ស្របតាមសរីរវិទ្យា ។នៅថ្ងៃទី 6 ខែ ឧសភា ឆ្នាំ 1954 ដែលមានផ្ទៃមេឃងងឹតឈ្លប់ នោះក្ដីសង្ឃឹមដ៏ធំរបស់ រ៉ចជឺ បាននីស្ដឺ បានកើតឡើង ! គាត់បានទៅដល់គំនូសផ្ដាច់ព្រ័ត្រក្នុងថេរវេលា 3 នាទី 59.4 វិនាទី គឺបានបង្កើតឯកត្តកម្មពិភពលោកថ្មីមួយ ។ក្ដីសង្ឃឹមគាត់គឺដើម្បីរត់ក្នុងចម្ងាយ 1.61 គ.ម. ដោយប្រើពេលតិចជាងបួននាទី បានក្លាយទៅជាជាក្ដីស្រមៃដែលសម្រេចបានដោយការហ្វឹកហាត់ ការខិតខំ និងការលះបង់ ។

ក្តីសង្ឃឹមអាចបំផុសឲ្យមានក្តីស្រមៃ ហើយជំរុញយើងឲ្យស្គាល់ពីក្តីស្រមៃទាំងនោះ ។ តែក្តីសង្ឃឹមតែម្យ៉ាង មិនអាចធ្វើឲ្យយើងជោគជ័យឡើយ ។ មានក្តីសង្ឃឹមដ៏ថ្លៃថ្នូរជាច្រើនត្រូវបានកន្លងផុតទៅដោយទទេស្អាត ដោយសារតែភាពខ្ជិលច្រអូស ។

ក្នុងនាមជាឪពុកម្តាយ ក្តីសង្ឃឹមដ៏ជ្រាលជ្រៅរបស់យើងគឺផ្តោតលើកូនចៅយើង ។ យើងសង្ឃឹមថាគេនឹងចម្រើនវ័យឡើងក្នុងជីវិតត្រឹមត្រូវនិងសុចរិត ។ក្តីសង្ឃឹមបែបនេះអាចត្រូវបំផ្លាញដោយងាយ បើយើងមិនធ្វើជាគំរូល្អនោះ ។ មានក្តីសង្ឃឹមតែម្យ៉ាង គឺពុំមែនមានន័យថាកូនយើងនឹងធំឡើងក្នុងភាពសុចរិតនោះទេ ។យើងត្រូវចំណាយពេលនឹងគេក្នុងរាត្រីជួបជុំក្រុមគ្រួសារ និងសកម្មភាពគ្រួសារល្អៗ ។ យើងត្រូវបង្រៀនគេឲ្យអធិស្ឋាន ។យើងត្រូវអានព្រះគម្ពីរជាមួយគេ ហើយបង្រៀនគេពីសារៈ-សំខាន់នៃគោលការណ៍ដំណឹងល្អ ។ មានតែវិធីនេះទេ ទើបក្តីសង្ឃឹមដ៏ស្មោះត្រង់យើងអាចសម្រេចទៅបាន ។

យើងមិនគួរបណ្តោយឲ្យភាពអស់សង្ឃឹមមកជំនួសក្តីសង្ឃឹមឡើយ ។ សាវកប៉ុលបានសរសេរថា យើងគួរ« ភ្ជួររាស់ដោយសង្ឃឹម » ( 1 កូរិន. 9:10 ) ។ការមានក្តីសង្ឃឹមធ្វើឲ្យជីវិតយើងប្រសើរឡើង ហើយជួយយើងឲ្យមើលឆ្ពោះទៅអនាគត ។ មិនថាយើងកំពុងភ្ជួររាស់ទីវាលដើម្បីដាំគ្រាប់ធញ្ញជាតិ ឬកំពុងរស់នៅក្នុងជីវិតនោះទេ វាជាការចាំបាច់ដែលយើងជាពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវមានក្តីសង្ឃឹម ។

ក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ក្តីសង្ឃឹមគឺជាក្តីប្រាថ្នានៃពួកអ្នកដើរតាមទ្រង់ ដើម្បីទទួលការសង្គ្រោះដ៏អស់កល្បតាមរយៈដង្វាយធួននៃព្រះអង្គសង្គ្រោះ ។

នេះពិតជាក្តីសង្ឃឹមដែលយើងត្រូវមានគ្រប់គ្នា ។ វាគឺជាអ្វីដែលធ្វើឲ្យយើងខុសប្លែកមនុស្សដ៏ទៃទៀតក្នុងពិភពលោក ។ ពេត្រុសបានទូន្មានដល់ពួកអ្នកជឿព្រះគ្រីស្ទកាលពីបុរាណថា « ឲ្យប្រុងប្រៀបជានិច្ចដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នក » ( ពេត្រុស ទី 1 3:15) ។

ក្តីសង្ឃឹមយើងលើដង្វាយធួនផ្តល់អំណាចឲ្យយើង ជាមួយនឹងជោគជ័យដ៏អស់កល្ប ។ ជោគជ័យបែបនេះជួយយើងឲ្យសម្លឹងមើលលើសពីជីវិតនេះ និងការសន្យានៃភាពអស់កល្ប ។យើងមិនចាំបាច់ត្រូវជាប់នៅក្នុងព្រំដែនដ៏ចង្អៀតនៃការរំពឹងទុកដែលផ្លាស់ប្តូរជាបន្តបន្ទាប់របស់សង្គមនោះទេ ។ យើងមានសេរីភាពមើលឆ្ពោះទៅសិរីល្អខាងសេឡេស្ទាល ដែលជាការផ្សារភ្ជាប់គ្រួសារយើងនឹងមនុស្សជាទីស្រឡាញ់ ។

ក្នុងដំណឹងល្អ ក្តីសង្ឃឹមស្ទើរតែពាក់ព័ន្ធជានិច្ចនឹងសេចក្តីជំនឿនិងក្តីសប្បុរស ។ ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ បានបង្រៀនថា ៖

« ក្តីសង្ឃឹមគឺជាជើងមួយក្នុងចំណោមជើងកៅអីដែលមានជើងបី ហើយជើងពីរទៀតគឺសេចក្តីជំនឿ និងក្តីសប្បុរស ។ កត្តាទាំងបីនេះធ្វើឲ្យជីវិតយើងមានលំនឹង ថ្វីបើយើងអាចនឹងជួបការលំបាកនៅពេលនោះក្តី ។ ( Dieter F. Uchtdorf « The Infinite Power of Hope » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 21 ) ។

ក្នុងជំពូកចុងក្រោយនៃព្រះគម្ពីរមរមន មរ៉ូណៃបានសរសេរថា ៖« ហេតុដូច្នោះហើយ ត្រូវតែមានសេចក្តីជំនឿ ហើយបើសិនជាមានសេចក្តីជំនឿ នោះត្រូវតែមានសេចក្តីសង្ឃឹមផង ហើយបើសិនជាមានសេចក្តីសង្ឃឹម នោះត្រូវតែមានសេចក្តីសប្បុរសផងដែរ ។

« ហើយលើកលែងអ្នករាល់គ្នាមានសេចក្តីសប្បុរស បើពុំនោះសោតទេ អ្នករាល់គ្នានឹងពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះឡើយ ហើយអ្នករាល់គ្នាក៏ពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នករាល់គ្នាគ្មានសេចក្តីជំនឿ ហើយអ្នកក៏ពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នកគ្មានសេចក្តីសង្ឃឹម » ( មរ៉ូណៃ 10: 20–21 ) ។

អែលឌើរ រ័សុល អិម ណិលសុន បានបង្រៀនថា ៖ « សេចក្តីជំនឿគឺផ្អែកលើព្រះយេស៊ូវគ្រីស្ទ ។ ក្តីសង្ឃឹមគឺផ្អែកលើដង្វាយធួន ។ ក្តីសប្បុរសគឺបង្ហាញនៅក្នុង‹ ក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ › ។ គុណសម្បត្តិទាំងបីនេះគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធប្រៀបបាននឹងសំណុំខ្សែក្នុងខ្សែភ្លើង ហើយវាមិនអាចនឹងមិនទទួលបានកិត្តិយសជានិច្ចនោះទេ ។ រួមគ្នាវាក្លាយទៅជាទំនាក់ទំនងជិតស្និទ្ធរបស់យើងទៅនឹងនគរសេឡេស្ទាល » ( Russell M. Nelson « A More Excellent Hope » *Ensign* ខែ កុម្ភៈ ឆ្នាំ 1997 ទំព័រ 61 ) ។

ពេលនីហ្វៃបានព្យាករពីព្រះយេស៊ូវគ្រីស្ទពេលបញ្ចប់កំណត់ហេតុរបស់ខ្លួន នោះគាត់បានសរសេរថា ៖

« ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះនិងមនុស្សគ្រប់រូប »( នីហ្វៃទី 2 31:20 ) ។

« ការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ »នេះដែលនីហ្វៃលើកឡើងគឺជាក្ដីសង្ឃឹមក្នុងដង្វាយធួនជាការសង្គ្រោះដ៏អស់កល្បដែលកើតឡើងដោយការលះបង់នៃព្រះអង្គសង្គ្រោះយើង ។ក្ដីសង្ឃឹមនេះបាននាំបុរសនិងស្ត្រីគ្រប់ជំនាន់ឲ្យធ្វើនូវរឿងដ៏អស្ចារ្យជាច្រើន ។ ពួកសាវកដែលបានធ្វើដំណើរលើផែនដី ហើយបានថ្លែងទីបន្ទាល់ពីទ្រង់ ហើយបានស្លាប់នៅក្នុងការបម្រើរបស់ទ្រង់ ។

ក្នុងគ្រាកាន់កាប់នេះ មានសមាជិកសាសនាចក្រកាលពីមុនជាច្រើននាក់បានចុះចោលផ្ទះខ្លួន ហើយដួងចិត្តគេគឺពោរពេញដោយក្ដីសង្ឃឹម និងសេចក្ដីជំនឿ ពេលគេបានធ្វើដំណើរឆ្លងកាត់វាលទំនាបដ៏ធំទៅកាន់ជ្រលងភ្នំ សលត៍ លេក នោះ ។

នាឆ្នាំ 1851 ម៉ារី មឺរ៉េយ មឹដហ្វ ជាស្ត្រីមេម៉ាយក្នុងវ័យហុកសិបប្រាំពីរឆ្នាំ បានចូលសាសនាចក្រនៅប្រទេសស្កុតឡែន ។ គាត់ជាស្ត្រីមាឌតូច មានកម្ពស់មួយម៉ែត្រសែសិប មានទម្ងន់តិចជាងសែសិបមួយគីឡូក្រាម មានកូនប្រាំបីនាក់ ហើយប្រាំមួយនាក់នៅរស់ដល់ធំ ។ដោយសាររូបរាងគាត់ កូនចៅរបស់គាត់បានដាក់ងារឲ្យគាត់ថា « លោកយាយតូច » ។

កូនប្រុសគាត់ ចន មឹដហ្វ និងភរិយាក៏ចូលក្នុងសាសនាចក្រដែរ ហើយបានមករដ្ឋយូថាហ៍ក្នុងឆ្នាំ 1852 ។ ជាមួយកូនៗពីរនាក់របស់ពួកគេ ។ ដោយមិនគិតអំពីការលំបាករបស់គាត់ បួនឆ្នាំក្រោយមក ចន បានផ្ញើប្រាក់ទៅឲ្យម្ដាយខ្លួន ដើម្បីគាត់អាចមកជួបជុំនឹងគ្រួសារនៅទីក្រុង សលត៍ លេក ។ ដោយសារក្ដីសង្ឃឹមដ៏ធំមួយ គឺធំជាងមាឌរបស់គាត់ នោះ ម៉ារីបានចាប់ផ្ដើមធ្វើដំណើរមួយដ៏លំបាកពីភាគខាងលិចទៅរដ្ឋ យូថាហ៍ ក្នុងវ័យចិតសិបបីឆ្នាំ ។

បន្ទាប់ពីដំណើរដ៏សុវត្ថិភាពមួយឆ្លងកាត់មហាសមុទ្រអាត្លង់ទិច ទីបំផុតគាត់បានចូលរួមនឹងក្រុម ម៉ាទីន ដោយថៃដន្យ ។ នៅថ្ងៃទី 28 ខែ កក្កដា ពួកអ្នកត្រួសត្រាយផ្លូវទាំងនេះបានចាប់ផ្ដើមដំណើរទៅភាគខាងលិច ។

ការរងទុក្ខរបស់ក្រុមនេះគឺមានភាពល្បីល្បាញណាស់ ។ ក្នុងចំណោមសមាជិកក្រុម 575 នាក់ ស្ទើរតែមួយភាគបួនបានស្លាប់ពីមុនពួកគេបានទៅដល់រដ្ឋយូថាហ៍ ។

មានមនុស្សជាច្រើននឹងត្រូវស្លាប់ បើគ្មានការជួយសង្គ្រោះដែលរៀបចំឡើងដោយប្រធាន ព្រិកហាំ យ៉ង់ នោះ ដោយបានបញ្ជូនរទេះ និងសម្ភារជាច្រើនដើម្បីស្វែងរកពួកបរិសុទ្ធដែលជាប់នៅកណ្ដាលព្យុះព្រិល ។

ម៉ារី មឹដហ្វ បានស្លាប់នៅថ្ងៃទី 2 ខែ តុលា ឆ្នាំ 1856 នៅជិតទីក្រុង ឈីមនី រ៉ក់ រដ្ឋ ណេប្រាស្កា ។ នៅទីនេះគាត់បានសុខចិត្តចុះចាញ់នឹងការនឿយហត់ អាកាសធាតុត្រជាក់ និងការលំបាកនៃដំណើរនេះ ។រូបកាយដ៏ទន់ខ្សោយរបស់គាត់មិនអាចទ្រាំទ្រនឹងការលំបាកដែលពួកបរិសុទ្ធទាំងនោះបានជួបប្រទះឡើយ ។ ពេលគាត់ជិតផុតដង្ហើម គាត់បានគិតពីគ្រួសារនៅ យូថាហ៍ ។សម្ដីចុងក្រោយនៃស្ត្រីត្រួសត្រាយផ្លូវដ៏ស្មោះត្រង់រូបនេះគឺ « សូមប្រាប់ ចន ផងថាខ្ញុំបានស្លាប់ជាមួយនឹងក្ដីប្រាថ្នាចូលរួមក្នុងក្រុងស៊ីយ៉ូន » ។

ម៉ារី មឺរ៉េយ មឹដហ្វ គឺជាគំរូពីក្ដីសង្ឃឹម និងសេចក្ដីជំនឿនៃអ្នកត្រួសត្រាយផ្លូវជាច្រើននាក់កាលពីសម័យមុន ដែលមានចិត្តអង់អាចធ្វើដំណើរទៅកាន់ភាគខាងលិច ។ដំណើរខាងវិញ្ញាណសព្វថ្ងៃនេះ ក៏តម្រូវឲ្យមាននូវក្ដីសង្ឃឹម ឬសេចក្ដីជំនឿមិនតិចជាងពួកអ្នកត្រួសត្រាយផ្លូវទាំងនោះកាលពីសម័យមុនដែរ ។ ឧបសគ្គរបស់យើងអាចខុសប្លែក តែការលំបាកមានភាពធំធេង ។

ខ្ញុំសូមអធិស្ឋានថា ក្តីសង្ឃឹមយើងនឹងដឹកនាំយើងទៅកាន់ការបំពេញនៃក្តីស្រមៃដ៏សុចរិតរបស់យើង ។ ជាពិសេស ខ្ញុំសូមអធិស្ឋានឲ្យក្តីសង្ឃឹមយើងក្នុងដង្វាយធួននឹងពង្រឹងដល់សេចក្តីជំនឿនិងក្តីសប្បុរស ហើយផ្តល់ឲ្យយើងនូវជោគជ័យដ៏អស់កល្បសម្រាប់ជីវិតនាអនាគតរបស់យើង ។ សូមឲ្យយើងគ្រប់គ្នាមាននូវការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះនេះ ខ្ញុំសូមអធិស្ឋានក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។